ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# មាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរ៣នាក់ ពីប្រទេសម៉ាឡេស៊ី

------------

ស្ថានឯកអគ្គរាជទូត**កម្ពុជា**ប្រចាំប្រទេស**ម៉ាឡេស៊ី** បានជួយដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៣នាក់** ដូចខាងក្រោម៖

(១) ពលការិនី **អ.ច.ណ** អាយុ៣១ឆ្នាំ មកពីស្រុកអង្គស្នួល ខេត្តកណ្តាល បានទៅម៉ាឡេស៊ីធ្វើការជាអ្នកបោសសំអាត ពីថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក នាងបានស្នើស្ថានទូតនៅថ្ងៃ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនីបានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសល់ និងលិខិតឆ្លងដែនជូននាងវិញ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ។

(២) ពលការិនី **ប.វ.ន** អាយុ៣៦ឆ្នាំ មកពីខណ្ឌទួលគោក រាជធានីភ្នំពេញ បានចាញ់បោកមេខ្យល់ ទៅធ្វើការជាអ្នកបោសសំអាតនៅម៉ាឡេស៊ី ពីខែកញ្ញា ឆ្នាំ២០១៦។ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត និយោជករបស់ពលការិនី បានយល់ព្រមឲ្យនាងទៅស្ថានទូត នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ជាមួយនឹងប្រាក់ខែដែលនៅសល់ លិខិតឆ្លងដែន និងសំបុត្រយន្តហោះ។

ពលការិនី **អ.ច.ណ** និង **ប.វ.ន** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៨** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង**០៧:៥០**នាទីព្រឹក តាមយន្តហោះលេខ AK536 ។

(៣) ពលការិនី **ស.ប.វ** អាយុ២៨ឆ្នាំ មកពីស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ បានទៅម៉ាឡេស៊ីធ្វើការងារផ្ទះ ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ តាមរយៈក្រុមហ៊ុនមួយនៅកម្ពុជា។ ដោយធ្វើការលំបាក នាងបានស្នើស្ថានទូត នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ ជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។ ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ និយោជករបស់ពលការិនី បានយល់ព្រមប្រគល់ប្រាក់ខែដែលនៅសល់ ជូនដល់នាង។

ពលការិនី **ស.ប.វ** នឹងមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៩** ខែ**ធ្នូ** ឆ្នាំ**២០១៦** វេលាម៉ោង **០៧:៥០**នាទីព្រឹក តាមយន្តហោះលេខ AK536 ៕

ភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ